# រាល់ថ្ងៃនីមួយៗ គឺមានតម្លៃណាស់

## ចូររៀនថ្ងៃនេះ - ទទួលបានជោគជ័យថ្ងៃស្អែក!



## ជួយអោយកូនលោកអ្នក ទទួលបានជោគជ័យក្នុងការសិក្សា : បង្កើតទម្លាប់ល្អក្នុងការទៅរៀនទាន់ពួកគេនៅតូចៗ

*ជោគជ័យក្នុងការសិក្សា គឺបានមកពីការទៅរៀនទៀងទាត់រាល់ថ្ងៃ!*

### តើលោកអ្នកបានដឹងទេ?

- ✓ ចាប់ផ្តើមពីកំរិតថ្នាក់មតេយ្យមក ការខានទៅរៀនច្រើនថ្ងៃ អាចធ្វើអោយកុមាររៀនពុំទាន់គេ។
- ✓ ការខានទៅរៀន 10 ភាគរយ (ឬប្រហែលជា 18 ថ្ងៃ) អាចធ្វើអោយមានការពិបាករៀនអានអក្សរ។
- ✓ កូនសិស្សអាចនៅតែរៀនមិនទាន់គេ បើគេគ្រាន់តែខានទៅរៀនមួយ ឬពីរថ្ងៃ ជារៀងរាល់ពីរបីសប្តាហ៍ម្តង។
- ✓ ការទៅរៀនយឺតម៉ោង អាចបណ្តាលអោយមានការខានទៅរៀនច្រើនថ្ងៃ។
- ✓ ការខានទៅរៀនអាចប៉ះពាល់ថ្នាក់រៀនទាំងមូល បើសិនជាគ្រូបង្រៀនត្រូវការបង្រៀនយឺតៗ ដើម្បីជួយអោយកុមារទាំងឡាយរៀនបានទាន់ព្រមៗគ្នា។

*ការទៅរៀនទៀងទាត់រាល់ថ្ងៃ ជួយអោយកុមារមានអារម្មណ៍ល្អចំពោះសាលារៀន និងចំពោះខ្លួនពួកគេ។ សូមចាប់ផ្តើមបង្កើតទម្លាប់ល្អនេះទាន់ពួកគេនៅរៀនសាលាព្រីស្គូល ដើម្បីអោយពួកគេមានការចេះដឹងភ្លាមៗ ថាការទៅរៀនទាន់ម៉ោង និងការទៅរៀនទៀងទាត់រាល់ថ្ងៃ គឺជាកត្តាសំខាន់។ ការទៅរៀនទៀងទាត់រាល់ថ្ងៃ នឹងជួយអោយកុមាររៀនបានពូកែក្នុងសាលាហៃស្គូល មហាវិទ្យាល័យ និងក្នុងវិស័យការងារ។*

### តើលោកអ្នកអាចធ្វើអ្វីខ្លះ

- ✓ ដាក់កំណត់ម៉ោងចូលគេងពីព្រលប់ និងក្រោកពីព្រលឹមអោយបានទៀងទាត់រាល់ថ្ងៃ។
- ✓ រៀបចំទុកដាក់ខោអាវ និងកាបូបសៀវភៅអោយបានហើយជាស្រេចពីល្ងាច
- ✓ ដឹងថ្ងៃចូលរៀនដំបូង និងធ្វើយ៉ាងណាអោយកូនលោកអ្នកទៅចាក់ថ្នាំបង្ការរោគអោយបានគ្រប់ចំនួនតាមការណែនាំ។
- ✓ ណែនាំកូនលោកអ្នកអោយស្គាល់គ្រូបង្រៀន និងមិត្តរួមថ្នាក់របស់ពួកគេ មុនសាលារៀនចាប់ផ្តើម ដើម្បីជួយអោយពួកគេស៊ាំនឹងការផ្លាស់ប្តូររបស់ពួកគេ។
- ✓ កុំអនុញ្ញាតអោយកូនលោកអ្នកនៅផ្ទះ បើសិនជាគេមិនគ្រុនទេនោះ។ សូមចាំទុកក្នុងចិត្តថា ការពោលថា ឈឺពោះ ឬក្បាលនោះ អាចជាសញ្ញាភ័យព្រួយ ហើយពុំមែនជាមូលហេតុត្រូវនៅផ្ទះនោះទេ។
- ✓ បើសិនជាកូនលោកអ្នកហាក់បីដូចជាភ័យព្រួយអំពីការទៅរៀន សូមជួបនិយាយជាមួយគ្រូបង្រៀន ខុនសិល្លើរសាលារៀន ឬមាតាបិតាផ្សេងទៀត ដើម្បីសួរយោបល់អំពីរបៀបធ្វើអោយពួកគេបាត់ភ័យខ្លាច ហើយចង់ទៅរៀន។
- ✓ បង្កើតផែនការបម្រុងទុកសំរាប់ការទៅរៀន បើសិនជាមានអ្វីមួយកើតឡើង។ សូមទូរស័ព្ទរកសមាជិកគ្រួសារ រកអ្នកជិតខាង ឬរកមាតាបិតាផ្សេងទៀតអោយអោយជួយដឹកកូនលោកអ្នកទៅរៀន។
- ✓ ធ្វើការណាត់ជួបពេទ្យ និងរៀបចំគំរោងធ្វើដំណើរកំសាន្តដែលមានរយៈពេលយូរ នៅពេលណាសាលារៀនបិទ ឬនៅពេលណាដែលកូនសិស្សឈប់សម្រាក។
- ✓ ដឹងចំនួនថ្ងៃដែលកូនលោកអ្នកខានទៅរៀន និងចំនួនថ្ងៃដែលកូនចូលរៀនយឺតម៉ោង

សំរាប់ព័ត៌មានថែមទៀត សូមចុចមើលក្នុងគេហទំព័ររបស់យើង : atschool.alcoda.org។

ដោយមានការអនុញ្ញាត ខិតប័ណ្ណនេះគឺយកលំនាំតាមឯកសារដែលបានផ្តល់អោយដោយផ្នែកការងារខាងវត្តមាន (www.attendanceworks.org)